**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

---

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០១.១៩៣/០៧ គ.ជ.ប/អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៧

# គ.ជ.ប លុបឈ្មោះបេក្ខជនចំនួន ៤ រូប ទៀតចេញពីបញ្ជីបេក្ខជន នៃគណបក្សនយោបាយចំនួន ២

គិតត្រឹមថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចលុបឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតចំនួន ៤ រូប ទៀតចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយចំនួន ២ នៅសង្កាត់ ចំនួន ២ ក្នុងក្រុង ភ្នំពេញ តាមការស្នើសុំរបស់បេក្ខជនផ្ទាល់ ។

បេក្ខជនទាំង ៤ រូប ដែល គ.ជ.ប បានលុបឈ្មោះចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក្នុងនោះមានចំនួន ២ រូប បានលុបចេញពីបញ្ជីបេក្ខជននៃគណបក្ស សម រង្ស៊ី នៅសង្កាត់ ច្បារអំពៅទី ២ ខណ្ឌ មានជ័យ ក្រុង ភ្នំពេញ និងចំនួន ២ រូប បានលុបចេញពីបញ្ជីបេក្ខជននៃគណបក្ស ហ៊្វុនស៊ិនប៉ិច នៅសង្កាត់ ផ្សារចាស់ ខណ្ឌ ដូនពេញ ក្រុង ភ្នំពេញ ។

សូមបញ្ជាក់ថា គិតមកដល់ពេលនេះ គ.ជ.ប បានលុបឈ្មោះបេក្ខជនចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ បានចំនួន ៣០ រូប ហើយគឺចំនួន ២៦ រូប គ.ជ.ប បានលុបកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧ កន្លងមកនេះ ហើយអគ្គលេខាធិការដ្ឋាន គ.ជ.ប បានផ្សព្វផ្សាយតាមរយៈសេចក្តីប្រកាសព័ត៌មាន លេខ ០១.១៩០/០៧ គ.ជ.ប/អគ្គ.ពស ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងផ្នែកព័ត៌មានសាធារណៈ ទូរស័ព្ទលេខ 023 214 231 / 012 855 018 & Fax 023 214 374 E-mail : necinfo@forum.org.kh Website: www.necelect.org.kh